អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## អ.វ.ត.ក និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចុះហត្ថលេខា លើអនុស្សរណៈ យោគយល់គ្នាស្តីពីការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធនៅ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធ នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដើម្បីទុកជាការរំឭកដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅទីនោះក្នុងរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ពិធីចុះហត្ថលេខានេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ វេលាម៉ោង ៩ ព្រឹក នៅសារមន្ទីរទួលស្លែងក្រោមអធិបតីភាព **ឯកឧត្តម ក្រាញ់ តូនី** ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃអ.វ.ត.ក និង **ឯកឧត្តម ជុច ភឿន** រដ្ឋលេខាធិការ ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

គម្រោងសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធនឹងចាប់ផ្តើមអនុវត្ត ពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ទៅ។ គម្រោងនេះទទួលបានការឧបត្ថម្ភពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ / ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (BMZ/GIZ) តាមរយៈ អង្គភាពគាំពារជនរងគ្រោះ នៃ អ.វ.ត.ក និងត្រូវអនុវត្តក្នុងក្របខ័ណ្ឌនៃវិធានការនានាមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការនៃគម្រោងសំណងរបស់ អ.វ.ត.ក។

វិធានការនានាដែលមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ គឺជាគំនិតផ្តួចផ្តើមដែលបានបង្កើតឡើង និងអនុវត្តសម្រាប់ជាផលប្រយោជន៍ជនរងគ្រោះទូទៅនៃរបបខ្មែរក្រហម។ វិធានការនេះ អាចត្រូវបានអនុវត្តនៅក្រៅដំណើរការនីតិវិធីតុលាការនៃ អ.វ.ត.ក ដែលមានភាពខុសប្លែកពីគម្រោងសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវតែមានការសម្រេចពីចៅក្រម។

កន្លងមក អង្គភាពគាំពារជនរងគ្រោះ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយ៖

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

១) មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) លើគម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងការកាប់សម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។

២) អង្គការក្តីករុណា (KdK) និង អង្គការយុវសន្តិភាព (YfP) លើគម្រោងតាំងពិព័រណ៍ចល័តស្តីពីការជម្លៀសប្រជាជនដោយបង្ខំនិង ការកាប់សម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។

៣) អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) លើគម្រោងស្តីពីការព្យាបាលតាមបែបសក្ខីកម្ម និងក្រុមជួយខ្លួនឯង។

៤) អង្គការយុវសន្តិភាព (YfP) លើគម្រោងស្តីពីមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅក្រាំងតាចាន់ ខេត្តតាកែវ។ គម្រោងទាំងនេះអាចអនុវត្តបាន ដោយមានមូលនិធិផ្តល់ជូនដោយ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ / ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (BMZ/GIZ) តាមរយៈអង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក។

អង្គភាពគាំពារជនរងគ្រោះ មានតួនាទីក្នុងការធ្វើ និងអនុវត្ត វិធានការ និងកម្មវិធីនានាដែលមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ ដើម្បីផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយ។ ក្នុងករណីសមស្រប កម្មវិធីខាងលើនេះអាចនឹងអនុវត្តដោយមានកិច្ចសហការជាមួយនឹងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលស្ថិតនៅក្រៅក្របខ័ណ្ឌនៃអ.វ.ត.ក។


| **សំរាប់ពត៌មានបន្ថែមសូមទាក់ទង** |
| --- |
| លោក **នេត្រ ភក្ត្រា**<br>មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម<br>ទូរស័ព្ទដៃលេខ៖ ៨៥៥ (0) ១២ ៤៨៨ ១៥៦<br>ទូរស័ព្ទលើតុលេខ៖ ៨៥៥ (0) ២៣ ៨៦១ ៥៦៤<br>សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh |

| **ទំនាក់ទំនងនៅអង្គភាពគាំពារជនរងគ្រោះ** |
| --- |
| លោក ឌី ឈុនសុង មន្ត្រីកម្មវិធីនៃអង្គភាពគាំពារជនរងគ្រោះ<br>សារអេឡិចត្រូនិច: dy.chhunsong@eccc.gov.kh |